# ការដាំធូរេន

# Durian Orchard






រៀបរៀងដោយលោក
វ៉ាន់ថាណា ប៊ូរសាប់
និងលោក មុនទ្រី
វង្សរក្សនិត

By Vann Thana
Busab and
Montry Vong
Phanith

ម.ឯ.ជ.ក AIDOC
Code: 178-001
Date:
Donated by:

# ដំណាំធូរេន

# មាតិការឿង

ទំព័រ


1. ការដាំកូនធូរេន.......01
2. ការជ្រើសរើសផ្ទៃដីដាំធូរេន.......02
3. ការជ្រើសរើសពូជ.......03
4. ការដាំ.......05
5. ការដាំធូរេនតាមរបៀបជីករណ្ដៅ.......06
6. ការដាំតាមរបៀបមិនជីករណ្ដៅ.......08
7. ការអនុវត្តន៍នៃការថែទាំកូនធូរេន.......10
8. ការអនុវត្តន៍នៃការថែរក្សានៅក្នុងរយៈពេលផ្ដល់ផ្លែផ្កាហើយ.......14
9. ការថែរក្សានៅក្នុងរដូវចេញផ្កា.......24
10. ការថែរក្សានៅក្នុងរដូវមានផ្លែហើយ.......31
11. ការប្រមូលផល និងការអនុវត្តន៍ក្រោយពេលប្រមូលផល.......35
12. រោគចម្លង សត្វល្អិតជាសត្រូវរបស់ធូរេន និងការបំផ្លាញ និងកិច្ចការពារ.......38
13. អាការៈខុសពីប្រក្រតីខ្លះៗរបស់ធូរេន.......54


អំណោយ

អ្នកឧកញ៉ា ចន្ទ័_សារុន

# ការដាំធូរេន

ធូរេនជាផ្លែឈើមួយដែលមានសារៈសំខាន់អាចដាំបាននៅតាមតំបន់ ដែលមានធាតុអាកាសក្តៅ និងសំណើមគឺនៅក្នុងភូមិភាគខាងកើត និងភូមិភាគខាងលិចនៃប្រទេសថៃឡង់ដ៍ ។ បច្ចុប្បន្នមានការពង្រីកដីនៅក្នុងការដាំធូរេនកាន់តែច្រើនឡើងៗ ដែលបណ្តាលមកពីបច្ចេកទេស (Techonolgy) នៃការដាំធូរេនមានការអភិវឌ្ឍន៍យ៉ាងខ្ពស់ ។ កសិករមានចំណេះដឹងមានការប្រើបច្ច័យនៃការផលិតបានយ៉ាងខ្ពស់ ធ្វើអោយផលិតផលធូរេនកើនឡើងយ៉ាងឆាប់រហ័ស និងបណ្តាលមកពីក្បួនកំណត់ដែលធូរេនជាផ្លែឈើនៅក្នុងតំបន់ក្តៅមានអាយុខ្លីក្នុងការរក្សាទុក រីឯផលិតផលដែលបានមកក្នុងរយៈពេលប្រហាក់ប្រហែលគ្នាជាច្រើនទើបធ្វើអោយតម្លៃធូរេនក្នុងកំឡុងពេលកន្លងមកមានទំនងជាចុះថោក ។

តែទោះជាយ៉ាងណាក៏ដោយ វាគឺជាផ្លែឈើដែលមានតម្លៃជូនកសិករប្រសើរជាងដំណាំផ្សេងៗទៀតដែរ សំរាប់អ្នកដែលផលិតធូរេនបានគុណភាពល្អ ឬអាចផលិតធូរេនដើមរដូវ ឬក្រៅរដូវបាន គេអាចលក់ផលិតផលធូរេនបានកំរៃយ៉ាងខ្ពស់ ។ ដូច្នេះកសិករត្រូវការយកចំណេះដឹងមកប្រើប្រាស់ អោយបានសមស្របនិងសភាពដី សភាពអាកាសធាតុនៅក្នុងចំការរបស់ខ្លួនឯងផង ។

# ការជ្រើសរើសផ្ទៃដីដាំធូរេន

<u>គួរគិតដល់</u> :

<u>ប្រភពទឹក</u> : ត្រូវមានប្រភពទឹកសាប ដើម្បីអោយដើមធូរេនបានគង់វង្សគ្រប់ៗឆ្នាំ ។

<u>សីតុណ្ហភាព និងសំណើម</u> :

ធូរេនចូលចិត្តអាកាសក្តៅ និងសំណើម សីតុណ្ហភាពដែលសមស្របនិងការដាំធូរេននោះគឺ 25-30 អង្សាសេ សំណើមពាក់ព័ន្ធទៅនឹងអាកាសធាតុប្រហែល 75-80% ។ បើសិនជាដាំនៅក្នុងផ្ទៃដីដែលមានអាកាសធាតុក្តៅគឺក្តៅៗពេក និងត្រជាក់ៗពេក និងមានខ្យល់បក់បោកខ្លាំងពេកនោះ និងបណ្តាលអោយជួបបញ្ហាស្លឹកជ្រុះ ឬស្លឹករោយ ។ ដើមធូរេនមិនលូតលាស់ល្អ ឬធំធាត់យឺត និងអោយផលយឺត ទិន្នផលតិចមិនស្មើនិងដើមទុន ។

<u>សភាពដី</u> :

គួរជាដីល្បប់ ដីល្បប់លាយខ្សាច់ ដីឥដ្ឋលាយខ្សាច់ដែលអាចច្រោះទឹកបានល្អ និងមានស្រទាប់ដីក្រាស់ (ជ្រៅ) ព្រោះធូរេនជាដំណាំដែលអន់ខ្សោយក្នុងការឃាត់ទឹកទុក ដីដែលប្រែះក្រហែងនៅចន្លោះពី 5.5-6.5 ។ បើសិនជាដាំធូរេននៅក្នុងសភាពដីខ្សាច់ចាំបាច់ត្រូវតែនាំយកអាចម៍ដីពីទីកន្លែងផ្សេងទៀតមកចាក់បន្ថែម ត្រូវដាក់ជីអាចម៍សត្វ (គោ ជ្រូក) និងត្រូវការដាក់ទឹកអោយបានជិតដល់ ជាពិសេសត្រូវមានប្រភពទឹកគ្រប់គ្រាន់ ។

# ធូជ (ពន្ធុ)







## គុណសម្បត្តិ

- មាំមួនចំពោះជំងឺរលួយឫស រលួយគល់មធ្យម
- ងាយចេញផ្កា
- សាច់រឹង រស់ជាតិឆ្ងាញ់ ពណ៌ស្អាត
- តម្លៃថ្លៃជាងធូជផ្សេងៗទៀត
- ជាប់ផ្លែល្អច្រើន
- ទំងន់ផ្លែល្អ
- សាច់ច្រើនជាងគ្រាប់ មានក្លិនតិច សាច់ម៉ដ្ឋរឹង មិនផុយ ផ្លែទុំហើយទុកបានយូរ
- មិនសូវមានសសៃឆ្មារ

## គុណវិបត្ត

- ចេញផ្កាមូល តែមិនសូវជាប់
- ជាសសៃឆ្មារងាយជ្រាប
- ងាយនឹងឆ្លងជំងឺតាមស្លឹក
- ងាយកើតជំងឺរលួយឫស និងរលួយគល់

| ធូជ (ធន្ទុ) | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
|  | × ផ្លែជាប់ល្អ<br>× មានផ្លែតម្លៃមធ្យម<br>× ផ្លែមានទំងន់ធ្ងន់ល្អ | × ងាយនឹងឆ្លងជំងឺ រលួយឫស រលួយគល់<br>× សំបកក្រាស់<br>× ជាសសៃច្រើនឆ្មារ<br>× ផ្លែទុំធ្លាប់បេះ ទុកមិនបានយូរ គូថផ្លែងាយនឹងជ្រុះបែក<br>× អោយផ្លែយឺតយ៉ាវ |
|  | × គ្មានបញ្ហាពិសសៃឆ្មារ ព្រោះជាធូជស្រាលប្រមូលផលមុនរដូវភ្លៀងជោគជាំ<br>× ឆាប់ចេញផ្កា ឆាប់ចាស់ ឬស្រគៀលលក់បានតម្លៃល្អក្នុងដើមរដូវវស្សា<br>× ផ្លែមូល ផ្លែជាប់បានល្អ<br>× អោយផលឆាប់<br>× របាស | × ងាយនឹងកើតជំងឺ រលួយឫស និង រលួយគល់ |

# ការដាំ

<u>រដូវកាលល្អនៃការដាំ</u> :

បើសិនជាមានការរៀបចំការផ្តល់ទឹកអោយមានប្រសិទ្ធិភាព ពោលគឺអាចថែទាំទឹកដល់ធូរេន អោយបានញឹកញាប់ ក្នុងរយៈពេលដាំដុះនោះគួរដាំពីខែមិនា ដល់ខែមេសា ។ ប៉ុន្តែបើសិន ជារៀបប្រព័ន្ធទឹកមិនទៀងទាត់ ឬមិនអាចផ្គត់ផ្គង់បានគួរដាំនៅពេលរដូវវស្សាវិញ ។

<u>ការត្រៀមដីដាំដុះធូរេន</u> :

1. ត្រូវដកដង្គត់ ដកឫសឈើចាស់ៗចេញពីកន្លែងដាំអោយអស់ :
   - ផ្ទៃដីខ្ពស់ មិនលិចទឹក ទឹកមិនដក់ : ត្រូវបំផ្លាញស្មៅតែម្យ៉ាង
   - ផ្ទៃដីខ្ពស់ មានកន្លែងដក់ទឹក : ត្រូវរាស់ផ្ទៃដីរាបស្មើ
   - ផ្ទៃដីទំនាបមានទឹកដក់ : ត្រូវធ្វើប្រព័ន្ធប្រឡាយទឹកហូរ ឬជីកប្រឡាយ

2. កំណត់ចន្លោះនៃការដាំ :

   នៅចន្លោះដើម និងចន្លោះជួរនីមួយៗចំងាយ 9 ម៉ែត្រ ដាំ 1 រ៉ៃ បាន 20 ដើម ។ ការធ្វើចំការដែលមានទំហំធំ គួរពង្រីកចន្លោះរវាងជួរអោយធំ ដើម្បីអោយងាយស្រួលក្នុងការនាំគ្រឿងចក្រផ្សេងៗចូលទៅធ្វើការបានតាមជួរនីមួយៗ ។

3. វាស់ផ្លូវ និងដោតដើមឈើតាមកន្លែងដាំដែលបានកំណត់ :

វាស់ផ្លូវ និងដោតដើមឈើតាមកន្លែងដាំដែលបានកំណត់ វាស់កំណត់ផ្លូវដោយគិតថា ផ្លូវដាំទំហំស្រឡះទូលាយរបស់ផ្ទៃដី ឬអាចកំណត់នៅក្នុងផ្លូវត្រង់កែងនិងផ្លូវថ្នល់ ឬ កំណត់ផ្លូវដាំទៅក្នុងទិសខាងកើត ឬទិសខាងលិច និងបើសិនជាមានការរៀបចំប្រព័ន្ធ ទឹក ត្រូវពិចារណាការគមធ្យោបាយដាក់ទុយោទៅក្នុងចំការផង ក្រៅពីនោះទើបដោតឈើ តាមប្រវែងដែលបានវាស់ ដើម្បីជីករណ្ដៅដាំបន្តទៅទៀត ។

វិធីដាំធូរេនមាន 2 យ៉ាងគឺ :

1. វិធីជីករណ្ដៅដាំអោយសមស្របទៅនិងចំការដែលគ្មានប្រព័ន្ធទឹក ។
2. វិធីដាំតាមរបៀបមិនជីករណ្ដៅអោយសមស្របទៅនិងចំការដែលមានប្រព័ន្ធទឹក មាន កត្តាល្អគឺសន្សំកម្លាំងពលកម្ម សន្សំប្រាក់កាសក្នុងការជីករណ្ដៅ ដីជ្រាបទឹក និងអាកាស ល្អធ្វើអោយឫសវាធាប់ធំធាត់ ។

## ០ ការដាំធូរេនតាមរបៀបជីករណ្ដៅ

1. ជីករណ្ដៅអោយមានទំហំធំ ហើយវែងនិងជំរៅរណ្ដៅនីមួយៗ 50 សង្ទីម៉ែត្រ ។
2. ផ្សំជីអាចម៍សត្វដែលមានចំណាស់ 5 គីឡូក្រាម និងជីហ្វូសហ្វាតកន្លះគីឡូក្រាម ច្របល់ជាមួយដីដែលបានជីកមកលើ បន្ទាប់មកទើបលុបទៅក្នុងរណ្ដៅអោយបាន កំពស់ប្រហែលពីភាគបីនៃរណ្ដៅ ។
3. ត្រៀមដើមផ្សាំដែលរឹងមាំ មិនកើតជំងឺ មិនមានសត្វល្អិតបំផ្លាញ និងមានត្រួយ ចាស់មួយគួរចុងក្រោយបំផុតឬសវាបែកខ្ញែកល្អ មិនឡៀនខ្ទង់នៅតាមគូថថង់ ។

4. ប្រើកាំបិតឆ្លៀលគូថថង់ចេញ ហើយដាក់ក្នុងរណ្ដៅអោយចំកណ្ដាល លៃអោយត្រង់ជួរជាមួយដើមផ្សេងៗ ។
5. ដាក់ថង់ដើមផ្សាំដែលបានកាត់គូថថង់ចេញ ហើយដាក់ក្នុងរណ្ដៅអោយចំ-កណ្ដាលលៃអោយត្រង់ជួរជាមួយដើមផ្សេងៗ ព្រមទាំងបញ្ឈាក់ពីកំពស់ខ្ពស់ទាបរបស់ដើមធូរេនអោយស្នាមសាករវាងឫស និងដើមឬកំពស់ដីមាត់ថង់អោយខ្ពស់ជាងដីមាត់រណ្ដៅតិចតួច ។
6. ប្រើកាំបិតឆ្លៀលចំហៀងថង់ទាំងសងខាងពីក្រោមឡើងទៅលើ ។
7. ទាញថង់ប្លាស្ទិកចេញប្រយ័ត្នកុំអោយដីក្នុងថង់បែក ។
8. កប់ ឬលប់ដីដែលនៅសល់ក្នុងរណ្ដៅ កុំលប់ដីអោយដល់ស្នាមសាកត្រួយ ឬស្នាមតភ្ជាប់ ។
9. បោះបង្គោលក្បែរដើមធូរេនដែលបានដាំហើយ ព្រមទាំងចងខ្សែផ្ដោបទុកដើម្បីការពារកុំអោយខ្យល់បក់បោករង្គើរ ។
10. បង្ហាប់ដីនៅតាមគល់ រកវត្ថុរុំគល់ហើយស្រោចទឹកតាមក្រោយអោយជោគ ។
11. រៀបចំបាំងអោយដើមធូរេនដែលទើបតែដាំ ដោយប្រើធាងដូង ធាងចាក កំទេចស្បូវភ្លាំង ធាងរកាំ ឬប្រើសំណាញ់បាំងថ្ងៃ ។ នៅពេលដែលដើមធូរេនបានចាក់ឫសមាំមួនល្អ ហើយគួរយកគំរបនោះចេញ ឬអាចដាំដើមពោធិដើម្បីអោយមានម្លប់ ដូចជាចេកក៏អាចផ្ដល់ម្លប់បានដែរ និងធ្វើអោយមានសំណើមនៅក្នុងចំការធូរេននោះបានយ៉ាងប្រសើរទៀតផង ជាពិសេសនៅក្នុងរដូវប្រាំងដែលមានអាកាសធាតុក្ដៅ និងមានកំដៅថ្ងៃខ្លាំងពេក ។
12. ផ្ដិះថង់ប្លាស្ទិកដែលរុំជុំវិញស្នាមសាកត្រួយ ឬស្នាមតភ្ជាប់ចេញនៅពេលដាំបានរយះពេលប្រហែល 1-2 ខែ ។

## វិធីជីករណ្ដៅ




ផ្សំដោយ :

- ដី
- ជីអាចម៍សត្វ (គោ ជ្រូក) 5 គីឡូក្រាម ក្នុងមួយរណ្ដៅ
- ជីថ្មហ្វូសហ្វាត កន្លះគីឡូក្រាមក្នុងមួយរណ្ដៅ

## ០ ការដាំធូរេនតាមរបៀបមិនជីករណ្ដៅ

1. ដាក់ជីហ្វូសហ្វាត 500 ក្រាម ឬប្រហែលមួយកំប៉ុងទឹកដោះគោកន្លះ ត្រង់កន្លែងដែលត្រូវដាំ កប់ដីស្ដើងៗ ។

2. នាំយកដើមធូរេនមកដាក់ ហើយចាំងដីក្បៀនៗមកពូនកប់ ។ ប៉ុន្តែបើសិនជាល្បប់ល្បាយខ្សាច់ ដីខ្សាច់ជាដីដែលមិនជាប់គ្នា គួររកវិធីជីករណ្តៅដាំវិញឬក៏ប្រើតាមរបៀបប្រឌិតផ្សេងៗ ។
3. វិធីប្រឌិតគឺនាំយកអាចម៍ដីពីកន្លែងផ្សេងៗមកដាក់ត្រង់កន្លែងត្រូវដាំ ពំនូកដីនោះមានប្រវែងបន្ទាត់ផ្ចិត 1 ម៉ែត្រ កំពស់ 15 សង្ទីម៉ែត្រ ។ បន្ទាប់មកកាយដីចំកណ្តាលពំនូកនោះហើយ ដាក់ជីហ្វូសហ្វាតចំកណ្តាល រួចកប់ដីស្តើងៗ ហើយយកដើមពូជធូរេននោះមកដាក់ចំកណ្តាលដែលបានកាយអោយត្រង់ ហើយកប់ដី និងបង្ហាប់ ។
4. ការយកថង់ចេញ ត្រូវប្រយ័ត្នប្រយែងកុំអោយដីក្នុងថង់បែក បើសិនជាអាចធ្វើបានគួរឆ្វៀលគូថថង់ចេញមុនសិន ហើយដាក់ដាំ ឆ្វៀលថង់ប្លាស្ទិកអោយរហែកពីកណ្តាលឡើងលើ រួចទើបដកថង់ប្លាស្ទិកចេញថ្នមៗ ។
5. ប្រយ័ត្នកុំកប់ដីអោយខ្ពស់ដល់កន្លែងសាកត្រួយ ឬកន្លែងផ្សាំតភ្ជាប់ ។
6. រកវត្ថុរំគល់ និងរៀបចំធ្វើរបាំងគ្របអោយដើមធូរេនដូចរបៀបជីករណ្តៅដែរ ។



របៀបដាំមិនជីករណ្តៅ

# ការអនុវត្តន៍នៃការថែទាំធូរេន

## ការអនុវត្តន៍នៃការថែរក្សាធូរេនមុនពេលចេញផ្លែផ្កា :

ជាប្រការសំខាន់ណាស់ដែលធ្វើអោយធូរេនមានការលូតលាស់បានយ៉ាងឆាប់រហ័ស ហើយផ្តល់ផ្លែផ្កាបានទាន់ចិត្តនោះគឺ :

1. នៅក្នុងកំឡុងពេលចាំទំរាំធូរេនអោយផ្លែផ្កាគ្រាដំបូង (ដំណាំធូបផ្សំ) គួរដាំបន្លែបង្ការដើម្បីរកថវិកាចំណូល ដោយយើងត្រូវជ្រើសរើសរកដំណាំណាដែលទីផ្សារត្រូវការជាងគេ ។

2. នៅពេលពិនិត្យឃើញធូរេនងាប់ក្រោយពីដាំត្រូវយកដើមថ្មីមកជួស ។

3. ការអោយទឹក គឺក្រោយពេលដាំរួចនោះរហូតដល់រដូវភ្លៀងធ្លាក់តែម្តង ។ បើសិនជាមានភ្លៀងធ្លាក់ច្រើនគួរធ្វើប្រព័ន្ធបង្ហូរទឹកនិងពិនិត្យមើលជុំវិញរណ្តៅដាំបើសិនជាឃើញមានដីស្រុត ឬស្រកជាត្លុកដែលអាចដក់ទឹកបាននោះ គួរពូនដីសារជាថ្មី ។ បើគ្មានភ្លៀងធ្លាក់គួរស្រោចទឹកអោយដីមានសំណើមជានិច្ច ។

   នៅឆ្នាំបន្តទៀត គួរថែរក្សាក្នុងការស្រោចដើមធូរេន (ផ្លែ) អោយបានជាប់ជានិច្ច និងនៅក្នុងរដូវប្រាំង គួរប្រើវត្ថុពូនគល់ដើម្បីអោយជួយរក្សាជាតិសើមដល់ដី ដូចជាចំបើងនិងស្មៅក្រៀម១ជាដើម ។

4. ការកាត់តុបតែងមែក :

   នៅឆ្នាំទី 1-2 មិនគួរកាត់តុបតែងមែកទេ ទុកអោយដើមធូរេនរីកលូតលាស់ពេញទំហឹងសិនចុះ ។ នៅឆ្នាំក្រោយ១ទៀតទើបកាត់តុបតែងដូចជាមែកស្ងួត (ងាប់) មែកខ្មែងមែកល្មៀនចេញមកក្រៅ និងកាត់មែកដែលកើតជំងឺចេញ បានថែរក្សាមែកខ្មែង

ដែលល្អដែលនៅស្របនិងផ្ទៃដី (មែកញៀកខ្មែងធំ ឬជាប្រភេទមុំទាល) ទុកអោយសមរម្យ ដោយអោយមែកនៅក្រោមបង្អស់នៅខ្ពស់ពីដីប្រហែលជា 80-100 សង្ទីម៉ែត្រ ។

5. ការការពារ និងបំផ្លាញរោគ :
រយៈពេលលាស់ស្លឹកខ្ចី គួរការពារនិងការបំផ្លាញដោយជំងឺឆ្លងតាមស្លឹកដូចជា ខ្ទួតមាន់ ខ្ទួតភ្លើងអង្រ្កង ។

នៅក្នុងរដូវវស្សា : ការបំផ្លាញមានជំងឺរលួយឫសនិងគល់ និងការរក្សាទុករុក្ខជាតិដូចជា ដាំស្មៅ ការពារដី ត្រូវសំអាតស្មៅនោះដោយប្រើកម្លាំងពលកម្មដូចជា ជំរះ ដក ឬ កាត់ព្យាយាមជៀសវាងកុំប្រើថ្នាំគីមី ព្រោះដើមធូរេននៅតូច ម្សៅគីមីនោះអាចមាន ផលប៉ះពាល់ដល់ដើមធូរេន ។

6. ការធ្វើម្លប់ ឬការបាំងម្លប់ :
នៅរដូវក្តៅ កំដៅថ្ងៃក្តៅខ្លាំងពេកធ្វើអោយស្លឹកធូរេនក្រៀម ឬស្រពោនបាន គួរធ្វើម្លប់បាំងថ្ងៃអោយដើមធូរេនដែលទើបនិងដាំថ្មីៗនោះ ។

7. ការដាក់ជីគួរអនុវត្តន៍ដូចតទៅនេះ :

- ដាក់ជីក្រោយពីការកាត់តុបតែងមែករួច ។
- ដាក់ជីព្រមទាំងសំអាតគល់ គឺជំរះស្មៅជុំវិញក្រោមដើមស្មើ និងទំហំមែកសាខារបស់ដើម ។ ព្រោះជីនិងបំផុសដីពីក្រៅក្រោមដើម ឬជាយដើមមកពូននៅក្រោមដើមអោយមានទំហំធំស្មើនិងមែកសាខារបស់ដើមធូរេន ឬដាក់ជីដោយប្រើរបៀបយកឈើស្រួចមកបុកដីអោយប្រហោង រួចហើយដាក់ជីតាមរន្ធនោះ ហើយលប់រន្ធអោយសព្វបរិមាណនៅក្រោមដើម ។ វិធីក្រោយនេះទោះបីជាប្រើ ឬចំណាយកម្លាំងពលកម្មច្រើនក៏ដោយ តែជួយបន្ថយបន្ថយនៃការខូតខាតជីដែលរលាយឬក៏ត្រូវទឹករសាត់បាត់បង់ដោយឥតប្រយោជន៍ដែរ ។

- ដាក់ជីអាចម៍សត្វមុនសិន ទើបដាក់ជីគីមីតាមក្រោយ ។
- គួរដាក់ជីក្នុងបរិវេណក្រោមដើមជុំវិញអោយសព្វ និងឃ្លាតគ្នាពីគល់ប្រវែង 30 សង្ទីម៉ែត្រ ឡើងទៅវាស៊ីសងទៅនិងទំហំមែកសាខារបស់ដើមធូរេន ។

**ចំនួន និងពេលវេលានៃការដាក់ជី :**

<u>ឆ្នាំទីមួយ</u> :

**ការដាក់ជីតាមគល់ 4 ដង [ (ដាក់មួយខែ អត់មួយខែ) (លោះគ្នា) ]**

| | |
|---|---|
| លើកទី 1-3 | ដាក់ជីអាចម៍សត្វ 5 គីឡូក្រាម ក្នុងមួយដើម (ចំនួន 1 ប៉ោត) |
| លើកទី 4 | ដាក់ជីអាចម៍សត្វ 5 គីឡូក្រាម ក្នុងមួយដើម (ចំនួន 1 ប៉ោត) ដាក់ជីគីមី 15-15-15 ឬ 16-16-16 ចំនួន 150-200 ក្រាម ក្នុងមួយដើម (កន្លះកំប៉ុងទឹកដោះគោឆៅ) |

**ឆ្នាំបន្តទៅទៀត (រយៈពេលដែលធូរេនមិនទាន់ផ្តល់ផល) :**

ការដាក់ជីតាមគល់ធូរេន 2 ដង (នៅដើមរដូវវស្សា និងចុងរដូវវស្សា)

| | |
|---|---|
| លើកទី 1 (ដើមរដូវវស្សា) | ដាក់ជីគីមី 15-15-15 ឬ 16-16-16 ចំនួនកន្លះគីឡូក្រាម ទៅដល់ 3 គីឡូក្រាមក្នុងមួយដើម ។ |
| លើកទី 2 (ចុងរដូវវស្សា) | ដាក់ជីអាម៍សត្វ 15-30 គីឡូក្រាម ក្នុងមួយដើម (ចំនួន 3-10 ប៉ោត) ដាក់ជីគីមី 15-15-15 ឬ 16-16-16 ចំនួនកន្លះគីឡូក្រាម ទៅដល់ 3 គីឡូក្រាមក្នុងមួយដើម ។ |

ចំនួនជីគីមីដែលដាក់នៅក្នុងម្តងៗយោងទៅលើទំហំដើម ដោយធ្វើការវាស់វែងពីគល់ដើមមកជាយទំហំដើមជាម៉ែត្របានប៉ុន្មាន ? គឺចំនួនជីគីមីដែលត្រូវដាក់ជាគីឡូក្រាមមានដូចតទៅ :

- ចំងាយពីគល់ដល់ជាយមែក 1 ម៉ែត្រ ដាក់ជី 1 គីឡូក្រាម
- ចំងាយពីគល់ដល់ជាយមែក 2 ម៉ែត្រ ដាក់ជី 2 គីឡូក្រាម
- ចំងាយពីគល់ដល់ជាយមែក 2.50 ម៉ែត្រ ដាក់ជី 2 គីឡូក្រាម




តំណែង និងចំនួននៃការដាក់ជី

# ការអនុវត្តន៏នៃការ
# ថែរក្សានៅក្នុងរយៈពេលផ្តល់ផ្លែផ្កាហើយ

វាជាប្រការសំខាន់ណាស់ដែលធ្វើអោយធូរេនចេញផ្កាហើយជាប់ផ្លែបានច្រើន និងផ្តល់ផលមានគុណភាពល្អ ។

## ๑ ការត្រៀមដើមអោយព្រមគ្នាដែលនឹងផ្កា

គឺជាការត្រៀមដើមធូរេនល្អគ្រប់គ្រាន់ មានអាហារគ្រប់គ្រាន់ ។ កាលណាធូរេនមានស្លឹកបែកមែកសាខាពេញដើម និងសភាពជុំវិញវាសមរម្យ គ្មានភ្លៀងដីមិនសូវមានសំណើម អាកាសធាតុចាប់ផ្តើមចុះត្រជាក់ធូរេនក៏ចាប់ផ្តើមចេញផ្កា ។ ដំណាក់កាលផ្សេងៗត្រូវប្រញាប់ដំណើរការបន្ទាប់ពីបានប្រមូលផលរួចដូចតទៅនេះ :

1. ការកាត់តែងមែក :
   បន្ទាប់ពីប្រមូលផលរួចត្រូវប្រញាប់កាត់មែកងាប់ មែកដែលមានជំងឺនិងខ្មែងដែលដុះនៅក្នុងមែកក្រពុំនោះចេញ ត្រូវលាបស្នាមកាត់នោះដោយថ្នាំគីមី ដើម្បីការពារពពួកមេរោគហ្វាំងគីស (Fingus) ឬពពួកវល្លិផ្អើក ។

2. បន្ទាប់ពីកាត់តែងមែក ត្រូវបំផ្លាញរុក្ខជាតិចង្រៃអោយអស់ហើយជ្រួំដីជាបន្ទាន់ :
   - ដាក់ជីអាចម៍សត្វ 15-50គីឡូក្រាម ក្នុងមួយដើម (ប្រហែល 3-10ប៉ោត)
   - ជីគីមី 15-15-15 ឬ 16-16-16 នៅអត្រា 3-5 គីឡូក្រាម ក្នុងមួយដើម

   ដើមធូរេនដែលគ្មានការលូតលាស់ល្អ ត្រូវការដាក់ជីគីមីអោយច្រើនជាងដើមធូរេនដែលមានការលូតលាស់ល្អ ។ ដើមធូរេនដែលបានផ្តល់ផលិតផលច្រើន

(ដើមយូរឆ្នាំ) គ្រាមកនោះត្រូវការជីច្រើនជាងដើមធូរេនដែលទើបតែផ្តល់ផលិត-ផល (ដើមធូរេនមានអាយុតិច) ។

3. ក្នុងរដូវវស្សា :

- ៳ បើសិនជាភ្លៀងធ្លាក់ច្រើនត្រូវធ្វើប្រឡាយបង្ហូរទឹកចេញពីកន្លែងដាំ
- ៳ បើសិនជាគ្មានភ្លៀងធ្លាក់ត្រូវស្រោចទឹកអោយដើមធូរេន
- ៳ ត្រូវកំចាត់រុក្ខជាតិ (ស្មៅ) ដោយកាត់ ឬដោយប្រើថ្នាំគីមី
- ៳ ត្រូវការពាររោគបំផ្លាញ មេរោគចំលងតាមសត្វល្អិតដូចជា រោគរលួយឫស ឬ រលួយគល់ រោគស្លឹកងាប់ ឬស្លឹករលួយ រោគអែនត្រាស់ណូស ខ្ទួតមាន់អង្គ្រង និងខ្ទួតភ្លើង ។

4. នៅចុងរដូវវស្សា :

- ៳ នៅពេលមិនសូវមានភ្លៀងធ្លាក់ត្រូវដាក់ជីគីមី 8-24-24, 9-24-24 ឬ 17-24-12 ចំនួន 2-3 គីឡូក្រាម ក្នុងមួយដើម ដើម្បីជំរុញធូរេនអោយឆាប់ចេញផ្កា ។
- ៳ ត្រូវកំចាត់រុក្ខជាតិនៅក្រោមដើមធូរេន បោសកំទេចស្មៅ និងស្លឹកធូរេនដែលជ្រុះចេញអោយស្អាតល្អ ដើម្បីអោយដីឆាប់ស្ងួត ។
- ៳ ត្រូវផ្អាកការផ្តល់ទឹក 10-14 ថ្ងៃ នៅពេលឃើញស្លឹកធូរេនចាប់ផ្តើមស្វិតត្រូវអោយទឹកបន្តិចម្តងៗ ដើម្បីអោយដើមធូរេនស្ទុះអោយភ្នែកចេញផ្កា កុំអោយ ខ្វះខាតទឹកយូររហូតស្លឹកលឿងជ្រុះ ព្រោះភ្នែកចេញផ្កាមកមិនល្អនិងប្រយ័ត្នកុំអោយទឹកច្រើនពេក ព្រោះកញ្ចុំផ្កាអាចក្លាយជាស្លឹកបាន ។

វិធីអោយទឹកដែលសមរម្យនោះគឺផ្តល់បែបមិនជោគជាំ ហើយលោះពេលគ្នាត្រូវសង្កេតមើលកល្ខណៈរបស់ស្លឹក និងផ្កា ។ ពេលឃើញផ្កាជាលក្ខណៈស្រដៀង

ពងត្រីច្រើនគ្រាន់បើហើយ ទើបផ្ដល់ទឹកអោយច្រើនឡើងជាបន្តបន្ទាប់រហូតអោយមានការស្រោចទឹកជាសភាពប្រក្រតីវិញ ។

## ដំណាក់កាលនៃការលូតលាស់របស់ផ្កាធូរេន



រយៈពេលផ្កាធូរេនមាន
សភាពជាពងត្រី



រយៈផ្កាជារបៀបជើងកណ្ដុរ

ផ្កាចាប់ផ្ដើមឃើញកញ្ចុំតូចៗស្រដៀងនិងពងត្រី មានពណ៌ត្នោតលាយពណ៌ខៀវរយៈពេលក្រោយមកផ្កាស្រដៀងនិងពងត្រីដែលលូតលាស់ចេញផ្កាតូចៗមករាង :



រយៈពេលប្រភេទក្បាលដែកគោល ធាងផ្កាចេញវែងនិងកញ្ចុំផ្ការីកធំឡើងតិច
តួចថៃរក្បាលក្ខណៈជាក្បាលដែកគោល



ពេលស្រដៀងឡៀវអាវផ្កាធូរេន លូតលាស់មានរាងមូល
ស្រដៀងទៅនឹងឡៀវ អាវចិន



រយៈពេលស្រដៀងនិងត្រប់ពុតញ្ញង ធាងផ្កាធ្លាក់វែង
ឃើញច្បាស់ដូចចង្ក្រាមត្រប់ពុតញ្ញង



ពេលស្រដៀងនិងបណ្តោងកងដៃ ផ្កាលូត លាស់យ៉ាងឆាប់រហ័សពេញ
ទំហឹងផ្កា ផ្កាមានពណ៌ប្រផេះលាយពណ៌ខៀវ ពន្ទុដែលនៅខាងក្នុងនឹងលូតលាស់
រុញផ្ការអោយស្រួចចេញមកតិចតួចហើយ មានលក្ខណៈជាបណ្តោងកងជើងកូនក្មេង



រយៈពេលចេញផ្កាសជាវេលាដែលផ្កាធ្លូវនេជិតរីក



ពេលផ្ការីក ផ្កាធូរេននឹងរីកពិន្ទុនៅពេលរាត្រី



លក្ខណៈកញ្ចុំផ្ការបស់ធូរេន
ដែលបានទទួលទឹកច្រើនពេកនៅក្នុងរដូវចេញផ្កា

## ១ ការថែរក្សានៅរដូវចេញផ្កា

1. ការពិនិត្យមើលការផ្តល់ទឹក :

- នៅពេលផ្ការនេចេញផ្ការយៈពេលជាពងត្រីមានចំនួនច្រើនបង្គួរ ហើយក៏ចាប់ផ្តើមផ្តល់ទឹកអោយច្រើនឡើងរហូតមានសភាពជាប្រក្រតី ។
- ពេលចេញផ្កា 7-10 ថ្ងៃ (ស្រដៀងទៅនិងបណ្តោងកងដៃ) រហូតទៅដល់ផ្ការីក និងពេលចេញត្រួយត្រូវបន្ថយការស្រោចទឹក 2 ភាគ 3 តាមប្រក្រតី ។
- ចាប់ផ្តើមផ្តល់ទឹកច្រើនក្នុងលំដាប់ប្រក្រតីបាន បន្ទាប់ពីបង្កាត់ពិន្ទុបាន 3 សប្តាហ៍មក ។

2. ការកាត់តែងផ្កា :

ដើម្បីសល់ផ្កាធូរេនទុកនៅក្នុងចំនួន និងតំណែងដែលសមរម្យ :

- កាត់ផ្កាដែលនៅតាមមែកតូចៗ ឬចុងមែកចេញ ។
- គួរកាត់តែងនៅពេលផ្កាធូរេននៅក្នុងចន្លោះពេលផ្កា មានលក្ខណៈជាគ្រាប់ពុតញ្ញូង ដល់ពេលផ្កាមានលក្ខណៈជារណ្តោងកងដៃ ។
- បើសិនមានផ្កាច្រើនក្នុងទងជាមួយគ្នា ត្រូវកាត់អោយសល់ចំនួនផ្កាបានសមរម្យនៅក្នុងតំណែងណាដែលត្រូវការ ។
- បើសិនជាមានផ្កា 2 ផ្នែក ឬក្រុមចំនួនផ្សេងគ្នាត្រូវកាត់ផ្កាផ្នែកណាមួយដែលមានចំនួនច្រើនអោយនៅសល់តិចតួច តែបើសិនជាផ្កាមានចំនួនតិចចាំបាច់ត្រូវទុកផ្កាវៀងៗខ្លួនតាមការគួរ ។
- ទុកផ្កាក្រុមជាមួយគ្នាលើទងជាមួយ ។
- ទុកផ្កាក្រុមជាមួយគ្នាលើទងដែលនៅជិតគ្នា ។

- បើសិនជាទុកផ្កាក្រុមផ្សេងគ្នាលើទងជិតគ្នា ត្រូវពិចារណាថាទុកប្រភេទណាមួយច្រើនជាង ដូច្នេះត្រូវកាត់តែងមែកនោះអោយសល់ច្រើនជាងទៅជាការស្រេច ។
- ក្នុងពូជធូរេនឈ្មោះ ឆះនី គួរកាត់តែងអោយសល់តិចតួចនៅពេលកាត់ ព្រោះ ផ្កាធូរេនពូជឆះនីមានភាគរយតិចណាស់ប្រការដែលមានកញ្ចុំផ្ការួមជាមួយក្រុមនោះធ្វើអោយមានអនុភាពបិតស្រូបយកជីជាតិបានល្អ ។



លក្ខណៈកញ្ចុំផ្ការបស់ធូរេន

ដែលបានទទួលទឹកច្រើនពេកនៅក្នុងរដូវចេញផ្កា



ប្រការដែលមិនកាត់តែងផ្កាធ្វើអោយដើម
ធូរេនត្រូវខាតបង់ជីជាតិទៅចិញ្ចឹមផ្កា ទាំងនោះជាចំនួនច្រើន



ផ្កាធ្មេញត្រូវកាត់តែងអោយសល់
ចំនួនតិចនិងតាមបច្ចេកទេសល្អ និងសមរម្យ

3. ការកាត់តែងផ្កា :

ដង្កូវស៊ីមែកផ្កា កូនខ្ចត ជំងឺរលួយផ្កា និងជំងឺផ្កាក្រៀម ឬស្ងួត ។

4. ការជួយអោយផ្កាធូរេនជាប់ផ្លែបានល្អ អនុវត្តន៍បាន 2 យ៉ាងគឺ :

4.1. ជួយបង្កាត់ពន្ធុ ដោយប្រើពន្ធុឈ្មោលដែលយកចេញពីប្រភេទពូជខុសគ្នាដោយ :

- ប្រជុំ ឬត្រៀមយកពន្ធុឈ្មោលនៅម៉ោង 19:00-19:30 កាត់យកតែពន្ធុឈ្មោលដែលមានលំអងពន្ធុពណ៌សដែលជាប់នឹងផ្កាវា ។
- ត្រូវធ្វើការបង្កាត់ពូជចាប់ពីម៉ោង 19:30 ទៅដោយប្រើប្រដាប់ ឬចម្រោះទន់ៗទៅប៉ះនិងលំអងពន្ធុឈ្មោល ហើយទៅប៉ះនិងចុងផ្កាញីដែលមានលក្ខណៈមូល និងមានពណ៌លឿង ។

4.2. ត្រូវដាក់ជីតាមស្លឹកដែលមានធាតុកាល់ស្យូម (Cacrium) ប៊័រន់ ឬ Cacrium-born ប្រើតែជី born តែមួយ៉ាងក៏បានដែរ (ចំណាំ : born មានជាតិជាលោហធាតុ) នៅក្នុងរយះពេលដែលផ្កាមានរូបស្រដៀងនិងបណ្តោងកងដៃ ឬមានរយះពេលពី 10-15ថ្ងៃមុនផ្ការីក។


ផ្កាឈ្មោល
ផ្កាញី

## ០ ការថែរក្សានៅក្នុងរដូវមានផ្លែហើយ

1. កាត់តែងផ្លែ :

លើកទី 1 : ក្រោយពីផ្ការីក 3-4សប្តាហ៍ ត្រូវកាត់តែងផ្លែណាមួយដែលមានវៀចប៉េតប៉ត ផ្លែដែលមានទំហំតូច ឬផ្លែ ក្រុមផ្សេងៗគ្នា ។ ផ្លែដែលមានទំរង់មិនសមរម្យដូចជាផ្លែដែល មាននៅចុងមែក ឬទង នៅចំហៀងទង និងផ្លែជាប់គ្នាណែនតាន់តាប់កញ្ចុំធំៗ ត្រូវបេះយកផ្លែណាដែលមិនល្អចេញ ដោយទុកតែផ្លែណាដែលយើងត្រូវការពិតប្រាកដ 50 ភាគរយ (50%) ។

លើកទី 2 : ក្រោយពីផ្ការីកបាន 6-8 សប្តាហ៍ ត្រូវបេះផ្លែតូចៗជាងគេចេញ ផ្លែមានរាងសំប៉ែត និងផ្លែណាដែលមានបន្ទាក្រហម ។

លើកទី 3 : កាត់តែងលើកចុងក្រោយនេះគឺកាត់ផ្លែតូចៗចេញ ផ្លែវៀចប៉េតប៉តផ្លែតូចខ្ចិបត្រូវបេះចេញអោយអស់ អោយសល់តែផ្លែណាដែលមានរូបល្អហើយស្មើគ្នាក្នុងទំហំប៉ុនៗគ្នា ដែលត្រូវការពិតប្រាកដ ។

នៅពេលកាត់តែងផ្លែលើកក្រោយនេះរួចហើយ ត្រូវចងមែកដើម្បីការពារកុំអោយមែកបាក់ដែលផ្លែកាន់តែមានទំងន់ធ្ងន់ឡើង ឬចងផ្លែការពារផ្លែជ្រុះដីដែលបណ្តាលមកពីខ្យល់បក់ខ្លាំង ។

2. ការដាក់ជី :

- បន្ទាប់ពីផ្លែជាប់បាន 5-6 សប្តាហ៍ ត្រូវដាក់ជីគីមី 12-12-17 - 2 ឬជី 13-13-21 ឬ 4-16-24-24 ចំនួន 2-4 គីឡូក្រាម ដើម្បីអោយឆាប់រីកលូតលាស់ល្អ ។
- បន្ទាប់ពី 7-8 សប្តាហ៍ ត្រូវដាក់ជីគីមី 0-0-50 ចំនួន 1-2 គីឡូក្រាម ដើម្បីបន្ថែមគុណភាពសាច់ និងបន្ថែមរសជាតិឆ្ងាញ់ ។
- បើសិនជាដើមធូរេនខ្វះជីជាតិ ស្លឹកតូច ស្លឹកស្លេក មិនខៀវស្រងាត់ គួរអោយជីតាមស្លឹកបន្ថែមនៅក្នុងសប្តាហ៍ទី 5-10 បន្ទាប់ពីផ្ការីក ដើម្បីជួយអោយផ្លែធូរេនមានគុណភាពល្អឡើង ។

3. ការថែរក្សាអោយស្លឹកបែកស្លឹកខ្ចី :

បើសិនជាធុរេនបែកស្លឹកខ្ចីនៅក្នុងរដូវជាប់ផ្លែ ស្លឹកខ្ចីនិងផ្លែធូរេនដណ្តើមជីជាតិគ្នា និងធ្វើអោយផ្លែខូចដូចតទៅ :

| ធូរេនបែកស្លឹកខ្ចី | ផ្លែដែលកើតឡើង |
|---|---|
| អាទិត្យទី 3-5 បន្ទាប់ពីផ្ការីក | ក្តិបជ្រុះ |
| អាទិត្យទី 5-8 បន្ទាប់ពីផ្ការីក | ផ្លែវៀច |
| អាទិត្យទី 10-12 បន្ទាប់ពីផ្ការីក | សាច់ផ្លែខ្វះគុណភាព សាច់រឹង សាច់ខ្មៅរឹង មានសាច់បិពណ៌ |

- បើសិនជាជួបឃើញធូរេនមានបែកស្លឹកខ្ចី (លាស់ស្លឹកខ្ចី) ត្រូវពិនិត្យឃើញសំបកស្តើងៗហ៊ុមព័ទ្ធតាមភ្នែកចាប់ផ្តើមលូតលាស់ ឬហៅម្យ៉ាងទៀតថារយះកាលស្រដៀងនិងកន្ទុយត្រី ត្រូវប្រញាប់ប្រញាល់បាញ់ជីប៉ូតាស្យូមណៃ-

ជ្រៃត (Potassium/Nitrate) 13-05-45 ក្នុងអត្រា 150-300 ក្រាម ក្នុងទឹក 20 លីត្រ បើសិននៅតែឃើញវាល្វតលាស់ត្រួយដដែលគួរបាញ់ជី ឬថ្នាំនេះម្តងទៀតគឺម្តងៗក្នុងរយៈពេល 1-2 សប្តាហ៍ ។

* បើសិនជាធូរេនលាស់ស្លឹកខ្ចីក្នុងខណៈដែលធំពេញរូបរាងហើយត្រូវបាញ់ថ្នាំ ឬជីតាមស្លឹក (ជីជាតិជំនួយ) និងធ្វើអោយផ្លែធូរេនវិតតែមានគុណភាពល្អថែមទៀត ។



" ស្រដៀងកន្ទុយត្រី "

លក្ខណៈធូរេនបែកត្រួយ និងស្លឹកខ្ចី

4. ការផ្តល់ទឹក :

ត្រូវថែរក្សាផ្តល់ទឹកអោយសមហេតុសមផល នៅក្នុងដំណាក់ការកំពុងជាប់ផ្លែនេះជានិច្ច ។

5. ការកត់ត្រាថ្ងៃចេញផ្កា :

ធូរេននីមួយៗ និងដើមនីមួយៗនោះត្រូវធ្វើសញ្ញាទុកដែលខ្សែពណ៌ផ្សេងៗគ្នាក្នុងការចងមែកដែលជាប់និងផ្លែក្នុងដំណាក់កាលនីមួយៗ ដើម្បីងាយស្រួលក្នុងការប្រមូលផល និងងាយស្រួលក្នុងការដាក់ផែនការតាមទីផ្សារ ។

6. ការបំផ្លាញជំងឺ និងសត្វល្អិត :

ត្រូវពិនិត្យ និងការពារបំផ្លាញជំងឺរលួយផ្លែ ដង្កូវចោះផ្លែ ដង្កូវស៊ីគ្រាប់ផ្លែធូរេន អង្រ្កង ខ្ទួតភ្លើង ខ្ទួតម្សៅ និងខ្ទួតតូចខ្យង ។

# ការប្រមូលផល និងការអនុវត្តន៍ក្រោយពេលប្រមូលផល

ជ្រើសរើសបេះផ្លែធូរេនណាដែលចាស់តែប៉ុណ្ណោះ :

1. គួរបំផ្លាញរុក្ខជាតិស្មៅដើម្បីត្រៀមផ្ទៃដីអោយមានការងាយស្រួលក្នុងការប្រមូលផល
2. បេះផ្លែធូរេនដែលចាស់ហើយ ដោយពិនិត្យពីលក្ខណៈរបស់ផ្លែ និងអាយុរបស់ផ្លែ

លក្ខណៈផ្លែនៅពេលធូរេនចាស់ និងជួយដល់ការផ្លាស់ប្តូរដូចតទៅនេះ :

- ពណ៌របស់សំបក និងផ្លាស់ប្តូពីពណ៌ខៀវខ្ចីទៅជាពណ៌ត្នោត ឬពណ៌ខៀវចាស់តែផ្លែដែលនៅក្រៅមែកត្រូវកំដៅថ្ងៃច្រើន មានពណ៌ត្នោតខ្លាំងជាងផ្លែដែលនៅបាំងមែកដែរ ។
- ទងផ្លែវិតតែចាស់ឡើងជាពណ៌ត្នោតក្រមៅវែង ត្រង់កន្លែងតភ្ជាប់និងផ្លែលើ និងទងផ្លែក្រោប និងរីកហើមធំឃើញស្នាមតភ្ជាប់ក្រឡែត ។
- ចុងបន្លាក្រៀម ឬស្ងួតមានពណ៌ត្នោតបន្លាជ្រែកចេញ ដូរបន្លាហាក់ដូចជាគ្មានឃ្លាតគ្នា
- ពិនិត្យស្នាមញែកខាងលើខ្លែបសំបកឃើញច្បាស់ក្រឡែត លើកលែងតែពពួកពូជធូរេនទងវែង ឃើញស្នាមខាងលើមិនសូវច្បាស់លាស់ទេ ។
- ភ្លក់លិទ្ធទងធូរេនដែលចាស់ដល់កំរិត នៅពេលកាត់ទងក្បាលធូរេន ឬសំយុងចុះទៅដូបប្រទះឃើញទឹករងៃថ្លាៗ មិនស្អិតពេកដូចផ្លែធូរេនខ្ចីភ្លក់មើល នឹងមានរសជាតិផ្អែម
- ការគោះសំបក ឬចិតបន្លាផ្លែធូរេនដែលចាស់បំផុតនិងមានសម្លេងខ្លាំងគ្រលរៗស្រាល

ដូច្នេះនៅពេលដែលផ្លែធូរេនចាប់ផ្តើមទុំនឹងជ្រុះនោះជាសញ្ញាប្រាប់ថា ធូរេនដែលនៅសល់លើដើមក្នុងដីណាក់ដូចគ្នានោះក៏ចាប់ផ្តើមប្រមូលផលអាចបេះបានរហើយ ។

ការរាប់អាយុ :

ដោយរាប់ចំនួនថ្ងៃក្រោយពេលផ្ការីករហូតដល់ថ្ងៃដែលធូរេនចាស់ នោះអាចប្រមូលផល

បានដែលមានដំណាក់ការផ្សេងៗគ្នាទៅតាមពូជធូរេននីមួយៗគឺ :

| | | |
|---|---|---|
| ⁎ ពូជធូរេនក្រាក់ខុម (ឡេវ) | ចំណាយពេល | 90-100 ថ្ងៃ |
| ⁎ ពូជធូរេនឆះនី (ទោច) | ចំណាយពេល | 110-120 ថ្ងៃ |
| ⁎ ពូជធូរេនកានយ៉ាវ (ទងវែង) | ចំណាយពេល | 120-135 ថ្ងៃ |
| ⁎ ពូជធូរេនម៉នថង (ម៉នថង) | ចំណាយពេល | 140-150 ថ្ងៃ |

ការរាប់អាយុនេះនិងអាចមានការខុតិចតួច (ERROR) វាស៊ីសងទៅនិងសីតុណ្ហភាពរបស់អាកាសធាតុដូចជា អាកាសក្តៅ និងហួតហែង ធូរេននិងឆាវចាស់ភ្លៀងធ្លាក់ជោគជាំច្រើន ពេកធូរេននឹងចាស់យឺត (ក្រចាស់) ។

ដើម្បីងាយស្រួលក្នុងការចងចាំ និងមានខុសឆ្គងត្រូវកាត់ផ្លែខ្ចីចោលចេញ ។ កសិករគួរកត់ត្រាថ្ងៃដែលចេញផ្កា និងធ្វើសញ្ញាចំណាំតាមក្រុមនីមួយៗដូចតទៅនេះ :

- កត់ត្រាថ្ងៃដែលចេញផ្កាធូរេនរីកចំពោះពូជធូរេននីមួយៗ ។
- ធ្វើសញ្ញាក្រុមក្នុងពេលដែលយើងចាប់ផ្តើមចងមែកដោយខ្សែ គួរប្រើខ្សែពណ៌ផ្សេងៗគ្នាក្នុងការចងតាមក្រុមនីមួយៗ ទាំងនេះដើម្បីងាយស្រួលក្នុងការកាត់ធូរេនដែលចាស់ និងមានគុណភាពល្អផង ។

វិធីនៃការប្រមូលផល :

- កាត់ចំណងទងរបស់ផ្លែដោយកាំបិតមុត និងស្អាត បន្ទាប់មកហុចអ្នកចាំនៅខាងក្រោមកុំអោយផ្លែវាធ្លាក់ដី វិធីដែលនិយមជាងគេគឺប្រើខ្សែបង្អូត ឬប្រើបាវដោយប៉ាន់ធ្វើជាចង់សំរាប់ទទួលផ្លែ ។
- ហាមដាក់ផ្លែធូរេននៅលើដីក្នុងចំការនោះដើម្បីការពារមេរោគហ្វាំងគីស (Fungus) ដែលបណ្តាលអោយកើតជំងឺផ្លែរលួយនោះឆ្លងទៅនឹងផ្លែធូរេន ។
- ត្រូវសំអាត ជ្រើសរើសគុណភាព ជ្រើសរើសទំហំមុនធ្វើការលក់ដូរ ។

## ប្រការសង្កេតខ្លះក្នុងការជ្រើសរើសការប្រមូលផលធូរេន



# រោគចម្លងសត្វល្អិត
# ជាសត្រូវរបស់ធូរេន និងការបំផ្លាញ និងកិច្ចការពារ

ធូរេនជាផ្លែឈើដែលមានសត្រូវធម្មជាតិជាច្រើនរួមទាំងជំងឺ និងសត្វល្អិតជាច្រើនផងដែរ ។ ប៉ុន្តែបញ្ហាសំខាន់របស់ពពួកធូរេនបច្ចុប្បន្ននោះគឺអង្រ្កងរបស់ធូរេន មានការរីករាលជាច្រើននៅក្នុងរដូវប្រាំងជាប់គ្នាជាយូរ ចំពេលដែលធូរេនកំពុងចេញផ្កានិងជាប់ផ្លែ ធ្វើអោយផ្លែនិងផ្កាហិនហោចអស់ ។ ដង្កូវចោះគ្រាប់ផ្លែធូរេនធ្វើអោយខូចខាតចំពោះផលិតផលនៅក្នុងដែលហៀបនឹងប្រមូលផល និងក្រោយពីការប្រមូលផល ហ្វាំងគីសហៃផថប់ថូរ៉ាជាមេរោគដែលបណ្តាលអោយរលួយឫស និងរលួយគល់ និងរោគផ្លែរលួយ (ស្អុយ) ធ្វើអោយដើមធូរេនទ្រុឌទ្រោមរហូតដល់ងាប់បាន និងធ្វើអោយផ្លែធូរេនស្អុយរលួយខូចខាតបន្ទាប់ពីការប្រមូលផលរួច ។

អង្រ្កងធូរេន :

អង្រ្កងមានការរីករាលយ៉ាងច្រើននៅក្នុងរដូវងារ ឬរដូវរំហើយ ឬក្នុងរដូវវស្សាគ្មានភ្លៀង ឬមានភ្លៀតតិចដែលអាកាសធាតុហួតហែងនិងខ្យល់ខ្លាំង ហេតុនេះហើយអង្រ្កងមានឱកាសបឺតយកទឹកដែលនៅតាមបរិវេណមុខ ឬលើស្លឹករបស់ធូរេន ជាពិសេសនៅតាមទ្រនុងស្លឹកកណ្តាលស្លឹក ដោយមានឃើញសំណាកពណ៌សនៅជាប់និងលើស្លឹកជាម្សៅស្រដៀងនិងសំឡីទន់ និងធ្វើអោយស្លឹកជ្រុះ ។ បន្ទាប់ពីនោះមកធូរេននិងបែកស្លឹកខ្ចីគឺចំពេលដែលធូរេនរីកផ្កា ឬចាប់ផ្តើមជាប់ផ្លែ ធ្វើអោយផ្លែនិងផ្កាជ្រុះខូចខាតអស់ ។ ប៉ុន្តែបើសិនរដូវក្តិបហើយ និងធ្វើអោយផ្លែប៉េតប៉តវៀចមិនសមល្អ ។ ក្រៅពីនោះអង្រ្កងនៅតែបឺតយកទឹកពីផ្នែករបស់ផ្លែខ្ចី ស្លឹកខ្ចី មែកខ្ចីបានផងដែរ ។



អង្រ្កងជាសត្វដែលមានទំហំខ្សែមានពណ៌ត្នោតចាស់
មានជើង 8 មើលឃើញមានចំណុច តូចៗចល័តទៅមកនៅលើស្លឹករបស់ធូរេន

## វិធីគ្រប់គ្រងបែបគួបផ្សំ :

1. អនុរក្សសត្រូវធម្មជាតិទុកគ្រប់គ្រងអង្រ្កងតាមធម្មជាតិដូចជាស្រមោចខ្មៅ ខ្មូងអណ្ដើក សត្វរុយជើងវែង និងពីងពាង ។
2. បើសិនពិនិត្យជួបឃើញអង្រ្កងទន្រ្ទានពេញចំការត្រូវបាញ់ទឹកអោយសព្វដើម ដើម្បីជួយបន្ថយចំនួនអង្រ្កងបាន ។
3. នៅពេលដែលបានជួបអង្រ្កងកើនឡើងខ្ពស់ ត្រូវត្រួតពិនិត្យអង្រ្កងនៅលើស្លឹក ។ បើសិនជាជួបប្រទះអង្រ្កងចំនួនមធ្យម 10 អង្រ្កងក្នុងមួយស្លឹក ត្រូវប្រើជាតិគីមីដើម្បីបំផ្លាញពួកវាគឺ :

* ប្រូផារ៍ 30% អត្រា 30 មិល្លីលីត្រ ក្នុងទឹក 20 លីត្រ
* ហោកស៊ីថៃអ៊ះសក 2% អត្រា 40 មិល្លីលីត្រ ក្នុងទឹក 20 លីត្រ

(បន្ទាប់ពីបាញ់ប្រូផានរ៉ែកផរ៍ហើយ 5-7 ថ្ងៃ នៅពេលជួបឃើញពង និងកូនវា)

ខ្នុតមាន់

ខ្នុតនេះនៅពេលណាវាធំធាត់ពេញវ័យ វាពងដាក់ក្នុងស្រទាប់ស្តើងៗរបស់ស្លឹក ធ្វើអោយយើងឃើញជារង្វង់ពណ៌លឿង ឬពណ៌ត្នោតតាមស្លឹកជាក្រុមៗក្នុងមួយក្រុមៗមានចំនួនពី 8-14 រង្វង់ ។ បន្ទាប់មកពងនឹងញាស់ចេញជាកូនខ្មៅទំហំវែងប្រហែលជា 3 សង្ទីម៉ែត្រ និងមានព្រួយពណ៌សជាប់នៅតាមខ្លួនវាផង ជាពិសេសនៅផ្នែកខាងចុងនៃខ្លួនវាមានព្រួយសៗស្រដៀងនិងកន្ទុយមាន់ ។ សត្វល្អិតប្រភេទនេះត្រូវបានគេអោយឈ្មោះថា “ ខ្នុតមាន់ ឬ ខ្នុតមាន់ទោ ” នៅពេលវាមានវ័យពេញរូបរាងហើយ និងមានពណ៌ត្នោតលាយខៀវមានប្រវែងជា 5 សង្ទីម៉ែត្រ មានអាយុរស់នៅយូរទៅដល់ 6 ខែ ។ វាមិនសូវហើរចេញទេក្រៅពីត្រូវភាពរាំងខ្ទប់ជីវិតរបស់វា ។

សត្វល្អិតប្រភេទ វារុករាននៅបរិវេណ កន្លែងដាំធូរេនទូទៅរយៈពេលដែលទន្ទ្រានធូរេននោះគឺពេលដែលធូរេនកំពុងបែក ឬលាស់ស្លឹកខ្ចីៗនៅចន្លោះៗ ពាក់កណ្តាលខែឧសភាពាក់កណ្តាលខែវិច្ឆិកា ។



ត្រូវធ្វើការបំផ្លាញចោលនូវសត្វល្អិតខ្នួតមាន់នេះចោល

## លក្ខណៈនៃការបំផ្លាញចោល :

កូនខ្ចីនិងមេធំរបស់ខ្មូតមាន់គឺបឺតយកទឹកមកចិញ្ចឹមពីលើស្លឹកខ្ចីៗរបស់ធូរេន ដែលធ្វើអោយអន្តរាយដល់ធូរេនយ៉ាងច្រើន ធ្វើស្លឹកធូរេនអោយទៅជាស្នាមអុចៗ ពណ៌លឿង មិនរីកល្អតលាស់ និងមានផ្ទៃតូចៗល្អិតៗខុសពីធម្មតា ។ នៅពេលណាវារុករានយូរៗទៅស្លឹកវានឹងមានលក្ខណៈកោងរមួល ក្ងិក្ងក់ក្រៀម និងជ្រុះអស់នៅចុងបញ្ចប់ ។ ក្រៅពីនោះមកវាធ្វើអោយត្រួយខ្ចីៗក្រៀមស្វិត និងងាប់បានផង ។ កូនខ្ចីៗរបស់ខ្មូតមាន់ទោនេះនឹងបញ្ចេញសារៈជាតិសៗរបស់វាចេញមក ជាហេតុបណ្តាលអោយកើតជំងឺផ្សិតហ្វាំងគីស (Fungus) នៅតាមបរិវេណដែលមានសារៈជាតិពណ៌សនោះ ។

## វិធីនៃការព្យាបាលបន្ទាប់បន្សំ :

1. រក្សាសត្រូវតាមធម្មជាតិរបស់ខ្មូតមាន់ទុកសំរាប់ការពារខ្មូតមាន់តាមធម្មជាតិ ដូចជាខ្មូងអណ្តើកមានស្លាប ខ្មូងអណ្តើកមានពណ៌ទឹកក្រូច ខ្មូងអណ្តើកមានសញ្ញាយុទ្ធថាស្រមោចយក្ស (Ant lion) និងពីងពាង ។
2. ការជំរុញអោយដើមធូរេនលាស់ស្លឹកខ្ចីព្រមៗគ្នា ដោយដាក់ជីអ៊ុយរេ 46-0-0 ក្នុងអត្រា 2 គីឡូក្រាម ក្នុងមួយដើម និងជួយបន្ថយពេលវេលានៃការរុករានរបស់ខ្មូតមាន់ និងធ្វើអោយការគ្រប់គ្រងពេលវេលាបានព្រមគ្នាផង ។
3. ពិនិត្យមើលត្រួយខ្ចី និងស្លឹកធូរេននៅពេលណាបានខ្មូតមាន់ត្រូវប្រើថ្នាំជ័រស្អិត ពណ៌លឿងធ្វើជាអន្ទាក់ដើម្បីបញ្ឆោតមេធំៗដែលមកបំផ្លាញ ឬបាញ់ទឹកនៅលើស្លឹកខ្ចីដែលលាស់ហើយ ដើម្បីបន្ថយចំនួនខ្មូតមាន់ និងពិនិត្យឃើញជួបចំនួនត្រួយរបស់ធូរេនដែលបានបំផ្លាញដោយវាមានចំនួន 4 ត្រួយ ក្នុងមួយដើម ត្រូវប្រើសារធាតុគីមីមួយណាក៏បានដូចខាងក្រោមនេះ ។

- សៃហាឡូទ្រីនអិល (Cyhalotrine-L.) 25% អត្រា 10ម.ល ក្នុងទឹក20លរ
- អេនដូស៊ុលហ្វេន (Endosolene) 35% អត្រា 50 ម.ល ក្នុងទឹក20លីត្រ
- កាបូនស៊ុលហ្វេន (Caborsolfene) 20% អត្រា 50 ម.ល ក្នុងទឹក 50 លរ

ដង្កូវចោះគ្រាប់ធូរេន :

ជាប្រភេទដង្កូវមេអំពៅត្រី មានស្លាបពណ៌ត្នោតចាស់ មានចំណុចពណ៌លឿងលាយម្ខាង 3 ចំណុច គេតែងតែជួបមេធំៗនៅក្នុងចំការនៅពេលដែលផ្លែធូរេនអាយុបានប្រហែល 2 ខែ មេចាស់និងពងដាក់លើផ្លែធូរេនជិតៗ ក្បាលទងផ្លែពង្រាយតាមលំដាប់ ។ បន្តមកដង្កូវនោះនឹងចោះចូលទៅខាងក្នុងគ្រាប់នោះ ទីបញ្ចប់ចូលស៊ីគ្រាប់ដោយមិនប៉ះពាល់ដល់សាច់ធូរេននោះឡើយ លើកលែងតែមានឃើញស្នាមវាដើរតូចៗ ។ នៅចន្លោះរវាងសាច់និងសំបកខាងក្នុងដែលមានស្នាមខ្សែតូចៗ គ្រាប់ធូរេនដែលត្រូវបានបំផ្លាញដោយដង្កូវនោះក្នុងរយះពេលដែលគ្រាប់ក្នុងរឹងហើយ ដោយវាប្រើពេលវេលាដើម្បីបំប៉នខ្លួនវារហូតធំពេញវ័យនៅក្នុងគ្រាប់តែក្នុងរយះពេល 30 ថ្ងៃ តែប៉ុណ្ណោះ ។

ការបំផ្លាញដោយដង្កូវចោះស៊ីគ្រាប់ធូរេននោះ ហើយដង្កូវចង្រៃប្រភេទនេះនិងចោះចូលទៅក្នុងគ្រាប់ស៊ី និងបញ្ចេញកាកសំណល់ចេញមក ដើម្បីធ្វើអោយសាច់ធូរេនប្រឡាក់ប្រឡូសខូចខាតអស់ ។ ដង្កូវពេញវ័យមានទំហំវែងប្រហែលជា 4 សង្ទីម៉ែត្រ ។ ដង្កូវពេញវ័យនេះក៏ចូលទៅក្នុងស្រោមឌុកឌឿចោះចេញមកតាមផ្លែជារន្ធ និងទំលាក់ខ្លួនជាមួយនឹងឌុកឌឿចូលទៅក្នុងដី ហើយមានការយល់ច្រឡំថាដង្កូវចេញពីស្រោមឌុកឌឿនៅក្នុងវដ្តវបន្តបន្ទាប់ទៅ ។ ផ្លែធូរេនដែលត្រូវបានបំផ្លាញហើយ និងមានរន្ធដែលដង្កូវចោះនោះទីផ្សារមិនត្រូវការឡើយ ។

វិធីការការពារបន្ទាប់បន្សំ :

1. ដាក់ភ្លើងអំពូលដើម្បីបញ្ឆោតមេអំពៅ ដែលជួយបន្ថយនៃការរុករានបានខ្លះ លទ្ធផល

នៃការដាក់ភ្លើងធ្វើអោយយើងដឹងផងដែរថា មេអំបៅមាននៅក្នុងរដូវណាដើម្បីធ្វើការបាញ់ថ្នាំសំលាប់សត្វល្អិតនោះអោយបានត្រឹមត្រូវតាមរដូវកាល ។

2. ប្រើថ្នាំគីមីដូចជាកាបារីល (Cabarril) អេនដូស៊ុលហ្វែន (Endosolfere) ឬមេថាមិដូហ្វូស (Methamedofoss) ធ្វើការបាញ់ក្រោយពេលឃើញមេអំបៅដែលកំពុងរោមភ្លើងជាលើកដំបូង ។



ផ្លែដូរ្យេន

3. ការដឹកជញ្ជូនគ្រាប់ធូរេនពីកន្លែងមួយដែលមានការរុករានរបស់ដង្កូវចោះគ្រាប់ ដើម្បីយកទៅបណ្ដុះជាច្រើនដើមក្នុងការពង្រីកពូជនោះ គួរយកគ្រាប់ធូរេនទៅត្រាំជាមួយទឹកថ្នាំគីមីសិនដូចជាកាបារីល (Cabarril) មុនពេលយកទៅបណ្ដុះដើម្បីជួយសម្លាប់ដង្កូវដែលមាននៅក្នុងគ្រាប់នោះបាន ។




4. ថែរក្សាចំការអោយបានស្អាតល្អជានិច្ច ឧស្សាហ៍ពិនិត្យមើលចំការក្រោយពីធូរេនជាប់ផ្លែហើយ កាលណាជួបប្រទះឃើញផ្លែណាដែលសត្រូវបំផ្លាញឬផ្លែជ្រុះក្នុងចំការដែលមានការរុករានដោយដង្កូវចោះស៊ីគ្រាប់ធូរេន គួររើសទុកផ្លែនោះទៅដុតកំទេចចោលរាល់ថ្ងៃតែម្ដងទៅ ពីព្រោះក្រោយពីធូរេនជ្រុះមិនយូរប៉ុន្មាន បើសិនមានដង្កូវនៅខាងក្នុងគ្រាប់នោះ ដង្កូវនឹងចោះរន្ធចូលមកដើម្បីចូលស្រោមឌុកឌៀនៅក្នុងដី ។

ដង្កូវចោះផ្លែ :

ជាដង្កូវមេអំបៅមានទំហំតូចស្លាបពណ៌លឿងមានចំណុចពណ៌ខ្មៅ ចូលបំផ្លាញផ្លែធូរេនតាំងពីផ្លែតូចរហូតដល់ផ្លែធំ ដោយមេចាស់ពងនៅខាងក្រៅផ្លែធូរេន ។ នៅក្នុងរយៈពេលដំបូង

ដង្កូវញាស់ចេញពីពងថ្មីៗ និងស៊ីតេះៗ ឬច្រិបស៊ីនៅតាមសំបកលើផ្លែធូរេនមុន កាលណាវាធំឡើងវានឹងស៊ីចូលទៅខាងក្នុង ។ បើសិនជាចោះស៊ីចូលទៅក្នុងរហូតដល់សាច់ធូរេន និងធ្វើអោយសាច់នៅជុំវិញដែលដង្កូវចោះចូលទៅក្នុងនោះស្អុយរលួយ ពេលដែលធូរេនទុំនៅខាងក្រៅផ្លែធូរេននិងឃើញមានកាកសំណល់របស់ដង្កូវបានយ៉ាងច្បាស់ និងមានទឹករងៃហូរចេញពេលដែលធូរេនចាស់មែនទែន ដង្កូវក៏នឹងចូលទៅបំផ្លាញផ្លែដែលនៅជាប់គ្នាច្រើនជាងផ្លែដែលនៅមួយៗ ព្រោះដង្កូវដែលទើបតែញាស់ពីពងចូលចិត្តរស់នៅតាមកន្លែងដែលធ្លាប់រស់នៅនេះ ។

**វិធីនៃការការពារគ្រួបផ្សំ :**

1. រក្សាសត្រូវធម្មជាតិទុកការពារដង្កូវចោះក្បាលទង ផ្លែធូរេនតាមធម្មជាតិដូចជា ម្រេញពិជឃាតពីងពាង រុយធំ ឱម៉ាល់ ។
2. ប្រើអំពូលភ្លើកប្លូឡែថបញ្ឆោតមេធំដែលមកបំផ្លាញ ។
3. ការកាត់តែងផ្លែធូរេនកុំអោយមានច្រើន ឬជាប់គ្នាច្រើនហួសពេក ឬអាចប្រើវត្ថុដូចជាធាងដូង ឬកំទេចឈើការពារនៅចន្លោះផ្លែ ដើម្បីការពារមិនអោយមេធំពងដាក់ ឬដង្កូវលាក់ខ្លួននៅបាន ។
4. ក្រោយពីកាត់តែងផ្លែធូរេនលើកទី 3 នៅថ្ងៃជួបផ្លែត្រូវបានបំផ្លាញដោយពួកវាហើយត្រូវបាញ់ថ្នាំគីមីចំពោះដើមណាដែលត្រូវបានរុករានដោយដង្កូវចង្រៃ ដោយប្រើប្រភេទថ្នាំមួយណាក៏បានដូចខាងក្រោមនេះ :

- សៃហាឡូទ្រីន (Cyhalotrine-L) អ៊ែស 2.5% អត្រា 20 មិល្លីលីត្រ ក្នុងទឹកចំនួន 20 លីត្រ ។
- កាបូស៊ុលហ្វៀន (Cloborsofine) 20% អត្រា 50 មិល្លីលីត្រ ក្នុងទឹកចំនួន 20 លីត្រ ។
- ក្លរ៉ផៃរីហ្វូស (Clorpyrifoss) 40% អត្រា 50 មិល្លីលីត្រ ក្នុងទឹកចំនួន 20 លីត្រ ។

5. ផ្លែធូរេនដែលស្អុយរលួយ និងជ្រុះគួររើសទៅបំផ្លាញចោល ដោយដុតនិងភ្លើង ឬកប់ក្នុងដីជាការស្រេច ។

## ដង្កូវស៊ីក្បាលទងផ្លែ :

ដង្កូវស៊ីក្បាលទងផ្លែធ្វើអោយហិនហោច និងស៊ីនៅជុំវិញក្បាលទងផ្លែ ។ ក្រោមក្បាលទងផ្លែតិចតួច ។ បើសិនជាមានដង្កូវចូលទៅបំផ្លាញយ៉ាងច្រើន និងធ្វើអោយផ្លែរបួត ឬជ្រុះរបេះទងជ្រុះ បើជួបឬឃើញត្រូវបំផ្លាញចោលផ្លែកំពុងនៅខ្ចី ។

## វិធីថែរក្សាបែបគួបផ្សំ :

1. រក្សាសត្រូវធម្មជាតិទុកសំរាប់ថែរក្សាដង្កូវស៊ីក្បាលទងផ្លែធូរេន តាមធម្មជាតិដូចជាម្រេញពិជឃាត ស្ដេញាំង ឪម៉ាល់ ពីងពាង ។
2. ប្រើអំពូលភ្លើងប្លែកប្លុំឡែថបញ្ឆោតមេធំមកបំផ្លាញ ។
3. ក្រោយពេលរៀបចំកាត់តែងផ្លែលើកទី 3 មក ពិនិត្យមើលឃើញធូរេនក្រុមបំផ្លាញដោយពពួកវាពីចំនួន 4 ផ្លែ ក្នុងមួយដើមឡើងទៅត្រូវបាញ់ថ្នាំគីមីចំពោះដើមដែលត្រូវបំផ្លាញ ដោយប្រើថ្នាំមេថាមិដូហ្វូស (Methamedofoss) 60% អត្រា 30 មិល្លីក្រាម ក្នុងទឹកចំនួន 20 លិត្រ ។

## ជំងឺរលួយឫស និងគល់រលួយ :

ជាជំងឺដែលសំខាន់បំផុតសំរាប់ធូរេន ដោយធ្វើអោយខូចខាតដល់កសិករជាម្ចាស់ធូរេនយ៉ាងច្រើន ដើមដែលចាប់ផ្តើមមានរោគនិងជួបប្រទះឃើញស្លឹកមិនស្រស់បំព្រង និងផ្លាស់ប្តូរទៅជាពណ៌លឿងស្លាំងទីបំផុត ស្លឹកជ្រុះ ពេលដែលជួបប្រទះអាការៈបានបង្ហាញចេញនៅមកតាមស្លឹកអោយពិនិត្យគល់ដើម ។ មែកឬ ឫសបរិវេណដែលជារោគមានពណ៌នៅនឹងសំបកខ្មៅដូចជាត្រូវទឹកជារង្វង់ ឬជាផ្លូវទឹកហូរចុះទៅខាងក្រោម ឬជាតំណក់ទឹកនៅត្រង់

បរិវេណដំបៅដែលមានពណ៌ត្នោតលាយក្រហម ឬមានស្នាមបែកនៃដំបៅនិងមានទឹកជ័រហូរចេញមកពីក្នុងដើម នោះជាជំងឺខ្លាំងក្លាបំផុតហើយ ។ បើសិនជាមានកើតជំងឺនៅផ្នែកឫស និងពិនិត្យឃើញស្លឹកមានអាការៈពណ៌លឿងស្លាំង ឫសដែលស្អុយមានពណ៌ខ្មៅរលួយជាប់នឹងដាច់ ។

ហ្វាំងគីស (Fungus) ហ្វៃថប់ា ជាមូលហេតុរបស់ជំងឺអាចរីករាលដាលតាមខ្យល់ ទឹកតាមដី តាមស្លឹក មែកបង្កាត់ពូជ និងតាមផ្លែ ជាពិសេសនៅក្នុងរដូវវស្សាដែលមានសភាពជោគជាំខ្លាំង ដែលបង្ករអោយមានការរីករាលដាលលូតលាស់របស់រោគ និងការចូលទៅបំផ្លាញក្នុងដើមធូរេនយ៉ាងងាយស្រួលបំផុត ។

វិធីនៃការគ្រប់គ្រងបែបគួបផ្សំ :

1. រក្សាពួកហ្វាំងគីស ជ្រៃខូឌើម៉ា (Drycothema) (Drycothema fungus) ដែលជាហ្វាំងគីសប៉ារ៉ាស៊ីត ឬជាសត្រូវធម្មជាតិរបស់ហ្វាំងគីសហ្វៃថបថូរ៉ា នៅក្នុងដីដោយធ្វើអោយដីមានសភាពទាំងផ្នែករូបសាស្ត្រ (Physic)និងគីមីដោយមានសភាពជារស់ជាតិប្រៃ 6.5 សមស្របក្នុងការលូតលាស់របស់មេរោគហ្វាំងគីសជ្រៃខូឌើម៉ា (Drycothema) ដើម្បីជួយការពារពពួកហ្វាំងគីសហ្វៃថបថូរ៉ានៅក្នុងដីតាមធម្មជាតិ

   ប្រើមេរោគហ្វាំងគីសជ្រៃខូឌើម៉ាពីការផលិតបំបែកដោយគួបផ្សំជាមួយហ្វាំងគីស ជាមួយកន្ទក់និងអាចម៍សត្វក្នុងអត្រា 1:25:25 ភាគរយនាំភាពផ្សំនេះទៅទុកដាក់បាតរណ្តៅមុនដាំអត្រា 1 គីឡូក្រាម ក្នុងមួយរណ្តៅ ឬនាំទៅរោយជុំវិញគល់ដើមធូរេនដែលធំ ហើយអត្រា 5 គីឡូក្រាម ក្នុងមួយដើម ហើយស្រោចទឹកអោយជោគ ដើម្បីជួយការពារហ្វាំងគីសហ្វៃថបថូរ៉ានៅក្នុងដី ។

2. វិធីការកំណត់នៅពេលដែលជួបប្រទះអាការៈដើមដំឡូងតិចតួច ត្រូវចាំងយកកន្លែងដែលកើតជំងឺនោះចេញ ហើយលាបកំបោរក្រហមកន្លែងចាំងនោះ ។

3. សារៈជាតិគីមី នៅពេលជួបប្រទះអាការៈធ្ងន់ធ្ងរត្រូវកោសសំបកផ្ទៃលើបរិវេណស្នាមដំបៅចេញ ហើយលាបថ្នាំគីមីមេតាលែកស៊ុល (Methalecil) 25% អត្រា 50-60 ក្រាម ក្នុងទឹក 1 លីត្រ នៅក្នុងករណីដែលជួបប្រទះធ្ងន់ធ្ងរផ្នែកឫស ឬផ្នែកនៅកំពស់ខ្ពស់ៗឡើងទៅត្រូវប្រើជាតិហ្វូសហ្វ័រសអ៊ែរ័ស៊ិត អត្រា 10 សេសេ ក្នុងទឹកស្អាត 10សេសេ ផ្សំដាក់ក្នុងស៊ីរាំងចាក់ថ្នាំហើយនាំទៅចាក់ចូលក្នុងផ្នែកណាដែលកើតជំងឺ ។

មេរោគហ្វាំងគីសជាហេតុបណ្តាលអោយកើតរោគរលួយឫស និងរលួយគល់ វារីករាលដាល ឬចម្លងនៅពេលដែលដីមានសំណើមជោគជាំខ្លាំង អាកាសសំណើមមានភ្លៀងធ្លាក់ ទើបគួរមានការការពារចាប់ពីដំឡូងអោយហើយ ។

នៅពេលខ្លះបានរៀបចំចំការធូរេន ដោយជ្រើសរើសផ្ទៃដីកន្លែងដាំដែលមានដី ទឹកបានល្អ មានការកាត់តែងមែកធូរេនអោយខ្យល់អាកាសបក់ចេញចូលបានស្រួលល្អ ពន្លឺថ្ងៃចាំងបានគ្រប់ទិសទី មានពូនដីតាមគល់ធូរេនក្នុងលក្ខណៈដូចខ្នងអណ្តើកដើម្បីការពារមិនអោយស្ទះទឹកជាំនៅបរិវេណគល់ធូរេន ។

**ជំងឺធ្លូងតាមស្លឹក :**

ជំងឺធ្លូងតាមស្លឹកគឺជាជំងឺដែលជួបជានិច្ច និងចាត់ទុកថាជាជំងឺដែលប្រហាក់ប្រហែលសភាពធ្ងន់ធ្ងរ ទោះបីជាមិនធ្វើអោយដើមធូរេនងាប់ក៏ដោយ តែជាជំងឺដែលធ្វើអោយដើមធូរេនទ្រុឌទ្រោមនិងខាតទំរង់ដើមបាន ធ្វើអោយមែកធំងាប់ គេតែងតែជួបប្រទះនៅក្នុងកន្លែងដាំដែលមានទឹកជោគជាំច្រើននិងដើមធូរេនមានមែកស៊ុបទ្រុបណែនតាន់តាប់ ជាលក្ខណៈអាការៈហ្វាំងគីសចូលទៅបំផ្លាញស្លឹកខ្ចីបានយ៉ាងស្រួលនៅក្នុងរដូវវស្សា ។ ស្លឹកដែល

ត្រូវបានបំផ្លាញនិងមានលក្ខណៈជាចំណែកចុចៗ ដូចជាទឹកក្តៅរលាក និងផ្លាស់ប្តូរពណ៌ទៅជាពណ៌ត្នោតនៅពេលដែលស្លឹកចាស់ ស្លឹកដែលកើតជំងឺនឹងជ្រុះជាប់មកជាមួយទ្រនុងស្លឹកសែផ្ការពណ៌សថ្លារុំព័ទ្ធដូចជាសំបុកពីងពាង ។ បើសិនស្លឹកដែលកើតជំងឺទៅប៉ះពាល់ស្លឹកដែលនៅក្បែរនោះក៏នឹងកើតជំងឺតាមដែរ ។

វិធីគ្រប់គ្រង :

កាត់តែងមែកធូរេនអោយសមល្មម កុំអោយស្ពុកឬស្រឡះពេក និងនៅក្នុងរដូវភ្លៀងនៅក្នុងខណៈដែលធូរេនលាស់ស្លឹកខ្ចី គួរបាញ់ថ្នាំគីមីដូចជា កាបិនដាស៊ីមថៃរ៉ាំបិនដាស្ពូលគូបភើរអុកស៊ីដខីវរ៉ៃដឺ បាញ់គ្រប់ 5-7 ថ្ងៃម្តង ។ ផ្នែកពិសេសស្លឹកដែលត្រូវជ្រុះនៅបរិវេណគល់ដើម គួរប្រមូលមកធ្វើការដុតបំផ្លាញចោលអោយអស់ ដើម្បីបន្ថយការប្រមូលផ្តុំរបស់មេរោគហ្វាំងគីស និងធ្វើការរាតត្បាតរបស់មេរោគនៅក្នុងឆ្នាំក្រោយមានការអន់ថយចុះជាបន្តបន្ទាប់ ។

ជំងឺរលួយផ្លែ :

កើតមកពីមេរោគហ្វាំងគីស ហៃថបថូរ៉ា ជាហ្វាំងគីសប្រភេទតែមួយដែលធ្វើអោយកើតជំងឺរលួយឫស និងរលួយគល់សុទ្ធសឹងតែនៅក្នុងកន្លែងដែលមានការរុករាតត្បាតរបស់មេរោគរលួយឫស រលួយគល់ និងមានឱកាសកើតរោគផ្លែរលួយបានច្រើន ។ លក្ខណៈអាការៈហ្វាំងគីសនិងចូលទៅបំផ្លាញទាំងមុន និងទាំងក្រោយពីការប្រមូលផល ដោយនឹងឃើញមានអាការៈជាចំណុចពណ៌ត្នោតព្រៀងៗលាយពណ៌ប្រផេះនៅលើសំបក ហើយបំបែកខ្លួនរាតត្បាតទៅជារង្វង់ធំ ធ្វើអោយសំបកបែកតាមស្នាមបែករបស់ធ្មេញសំបករបស់ធូរេន ។

ផ្លែដែលកើតបំផ្លាញនៅក្នុងរយៈពេលនៃការប្រមូលផល បើសិនជាកើតមានច្រើននឹងជ្រុះមុនពេលកណត់ សំរាប់ផ្លែដែលទទួលមេរោគហ្វាំងគីសពីក្នុងកន្លែងដាំ និងបង្ហាញអាការៈ

នៅក្នុងរយៈពេលក្រោយនៃការប្រមូលផលក៏នឹងមានអាការៈដូចគ្នា ។ តែគេរមែងជួបអាការៈផ្លែរលួយ ស្អុយ ក្រៅពីបរិវេណផ្នែកចុងរបស់ធូរេន ។

វិធីនៃការគ្រប់គ្រង :

បាញ់ថ្នាំគីមីការពារផ្លែស្អុយដូចជាហ្វូស៊ីធីឡ័រល្លូមីនៀម ខែហ្វថាហ្វល ឬមេត្តាឡែកស៊ីលនៅក្នុងមុនការប្រមូលផលប្រហែលមួយខែ និងដើម្បីជាការការពាររោគផ្លែរលួយ និងកើតមានឡើងតាមក្រោយនៃការប្រមូលផល ដូច្នេះត្រូវធ្វើការប្រមូលផលធូរេនយ៉ាងប្រុងប្រយ័ត្ន និងមិនគួរដាក់ផ្លែធូរេននៅផ្ទាល់លើដី ព្រោះហ្វាំងគីសដែលនៅក្នុងដីអាចឆ្លងនៅតាមបន្ទាររបស់សំបកធូរេន ធ្វើអោយខូចខាតចំពោះធូរេននៅក្នុងចន្លោះការដឹកជញ្ជូន និងរងចាំការលក់ចេញបាន បើសិនជាចំការធូរេននោះមានការរុករានច្រើន ។ ផ្លែធូរេនស្អុយនិងជ្រុះនៅក្នុងចំការ និងជាកន្លែងសន្សំមេរោគ ធ្វើអោយកើតការរុករានរបស់មេរោគរលួយគល់តទៅ ដូច្នេះទើបគួរប្រមូលដុតបំផ្លាញចេញអោយអស់ ។

---

ជំងឺក្រាមៀ្យ :

ប្រការដែលក្តិបធូរេនមានធូលីពណ៌ស។ ដូចជាមៀ្យនៅជាប់និងផ្លែនោះ ។ បើសិនជាកើតមានច្រើនឡើង។ យើងនឹងឃើញជាពណ៌សទាំងអស់តែម្តងធ្វើអោយផ្លែជ្រុះ ។ សំរាប់ផ្លែណាដែលមិនទាន់មានក្រាមៀ្យនោះច្រើន ឬនៅពេលផ្លែមានទំហំធំបន្តិចមកផ្លែនិងអាចលូតលាស់ធំបាន តែសំបកនិងមានលក្ខណៈជ្រុង។មិនស្អាត និងមានបន្លាទាល (មិនស្រួច) ជាងប្រក្រតី ។

វិធីគ្រប់គ្រង :

- ប្រមូលផ្លែជ្រុះមានមេរោគទៅដុតបំផ្លាញចោលចេញ
- បាញ់ថ្នាំគីមីពពួកដៃណូខែហ្វ បេណូមិល ឬការបេនដាស៊ុម

## ជំងឺច្រេះចាប់ :

ជំងឺនេះកើតមកពីស្លែដែលជារុក្ខជាតិប្រភេទទាបមួយផ្នែក បណ្ដាលអោយខូចខាតនៅក្នុងចំការដែលមានជាតិសើមខ្ពស់ គេតែងតែជួបប្រទះជំងឺនេះនៅនឹងស្លឹកនិងមែកដែលក្រោកជាអាការៈជាចំណុចតូចៗ ឬខ្នងពណ៌ប្រផេះខ្ចីលាយពណ៌ខៀវមានទំហំពី 0.3-1 សង្ទីម៉ែត្រ ហើយនិងផ្លាស់ប្ដូរជាពណ៌ត្នោតក្រហមស្រដៀងទៅនឹងច្រេះ ដើម្បីអោយស្លឹកធ្វើតេស្ដពន្លឺថ្ងៃបានតិច ប៉ុន្តែបើស្លែនោះចូលទៅបំផ្លាញតាមមែករបស់ធូរេន និងឃើញមានលក្ខណៈស្រដៀងកាំមញ្ញ ពណ៌ត្នោតក្រហមឡើងជាពណ៌ព្រាលៗតាមមែកទងរបស់ធូរេន បន្ទាប់មកសំបកធូរេននឹងក្រៀម និងបែកនៅទីបំផុត ធ្វើអោយត្រួយឬចុងមែកដំបៅនោះនឹងបន្ថយការលូតលាស់និងធ្វើអោយមែកនោះក្រៀមងាប់បាន ។

## វិធីគ្រប់គ្រង :

រោគនេះនឹងជួបប្រទះនៅក្នុងរដូវវស្សា ដែលមានសភាពសើមជោគជាំខ្លាំង និងជួបប្រទះនៅក្នុងចំការធូរេនដែលមិនធ្លាប់បាញ់ថ្នាំគីមីដើម្បីការពារ និងកំចាត់ជំងឺចម្លងតាមស្លឹកភាគច្រើន ។ ដូច្នេះនៅក្នុងដើមរយៈពេលដើមរដូវ ឬនៅក្នុងខណៈដែលធាតុស្លែនៅក្នុងពេលនោះជាក្រុមក្រហមៗ គួរបាញ់ថ្នាំគីមីការពារដូចជាតូភ្លើរីអុកស៊ុដក្លរ ។

---

## រោគក្រាពណ៌ស៊ីជម្ពូរ :

រោគនេះគេតែងជួបប្រទះច្រើននៅក្នុងកន្លែងដាំដែលមានសភាពសើមជោគជាំច្រើន និងដើមធូរេនមានមែកក្រពុំក្រាស់ឃ្មឹក និងជួបប្រទះអាការៈស្លឹកលឿងជ្រុះជាក្រុមៗ ដូចជាអាការៈមែកងាប់ និងជ្រុះស្លឹកដែលកើតមកពីមេរោគរលួយគល់ ។ ប៉ុន្តែបើសង្កេតមើល

មែកធ្មេននិងឃើញជាលក្ខណៈម្រម៉ៅពណ៌ស៊ីជម្ពូរំព័ទ្ធ ធ្វើអោយសំបករបស់មែកដែលកើតរោគនោះបែកនិងរបូតជ្រុះពីសាច់ឈើ បើសិនកើតជុំមែកនិងធ្វើអោយមែកធ្មេនក្រៀមងាប់នៅទីបំផុត ។

វិធីគ្រប់គ្រង :

* បើសិនជាហ្វាំងគីសចាប់ផ្តើមចូលទៅបំផ្លាញ ត្រូវចាំងនៅបរិវេណនៅកន្លែងដែលកើតមេរោគចូលបំផ្លាញនោះដុតវាចោលអោយអស់ ។ ហើយលាបស្នាមដំបៅដោយពពួកជាតិគួបពើរ៍អុកស៊ីដខ្លរ័រ៉ែដ ឬកំបោរក្រហម ប៉ុន្តែបើសិនជាមែកត្រូវប៉ះពាល់ទាំងមែកត្រូវកាត់មែកទាំងអស់នោះចោល ហើយនាំវាមកដុតបំផ្លាញចោលនិងលាបស្នាមដំបៅដែលកាត់ដោយសារៈធាតុគួបពើរ៍អុកស៊ីដខ្លរ័រ៉ែដ ឬកំបោរក្រហម ហើយត្រូវបាញ់ថ្នាំតាមមែកដែលនៅជិតគ្នាផង ដើម្បីការពារការរីករាលដាលពីមួយទៅមួយបាន ។

* គួរបានការកាត់តែងមែកក្រោយពីប្រមូលផលរួចគ្រប់ពេល ដើម្បីកំចាត់ដើមដែលគ្មានប្រយោជន៍នោះចោល ដើមធ្មេននឹងមានសភាពស្រឡះអាចទទួលកំដៅថ្ងៃបានគ្រប់គ្រាន់ទាំងអស់ និងមានអាកាសធាតុចេញចូលបានល្អ ដែលជួយបន្ថយការរាតត្បាតរបស់មេរោគបានមួយផ្នែកទៀត ។

## អាការៈខុសពីប្រក្រតីខ្លះៗរបស់ធូរេន

### ធូរេនស្រពាប់ស្រពោន (រញម) :

បណ្តាលមកពីធូរេនបានទទួលទឹកច្រើនហួសពេកនៅក្នុងរយះពេលមុនរដូវប្រមូលផល ធ្វើអោយស្អុល ឬខ្ចីមរបស់ផ្លែធូរេនជោរ ទន់ជ្រាយ និងគុណភាពរបស់ធូរេនមិនល្អ ។ ហើយទីផ្សារមិនត្រូវការផងនៅក្នុងរដូវភ្លៀងធ្លាក់ធ្ងន់ ។ ពូជធូរេនដែលជួបប្រទះជារោគស្រពាប់ស្រពោនដូចជាពូជធូរេន ឆះនី និងពូជ កានយ៉ាវ " ពូជទងវែង " ចំណែកឯពូជកង្កែបបើសិនជាភ្លៀងមិនធ្លាក់ជោគជាំពេកក៏មិនសូវមានបញ្ហាប៉ុន្មានទេ សំរាប់ពូជក្រាក់ខុម (ពូជឡេវ) មិនសូវមានបញ្ហាដែរព្រោះជាពូជស្រាល អាចបេះមុនរដូវភ្លៀងធ្លាក់ជោគជាំបាន ។

### សាច់ខ្មៅ និងសាច់ក្រិន :

ធូរេនសាច់ខ្មៅជាអាការៈខុសពីប្រក្រតី ដោយផ្នែកខាងចុងនៃសាច់ធូរេនរុំព័ទ្ធគ្រាប់នោះជាពណ៌ត្នោតខ្មោច (ត្នោតខ្មៅ) បណ្តាលមកពីការលូតលាស់របស់ផ្លែឆាប់រហ័សហួសហេតុ ពេកជីវជាតិដែលមកចិញ្ចឹមផ្លែមិនគ្រប់គ្រាន់នៅក្នុងរដូវដែលធូរេនកំពុងដាក់សាច់ ។ ដើមធូរេនមិនលូតលាស់ពេញលេញ ធ្វើអោយការផ្តល់ជីវជាតិទៅចិញ្ចឹមផ្លែមិនបានគ្រប់គ្រាន់ ។

សាច់ក្រិនជាអាការៈដែលសាច់ធូរេនរឹង មានពណ៌ស្លាំងខុសពីប្រក្រតី និងមានរស់ជាតិល្វីង អាចល្វីងតាមផ្នែកខ្លះៗ ឬល្វីងទាំងផ្លែតែម្តង ។ ដើមធូរេនមិនលូតលាស់គ្រប់គ្រាន់ជីវជាតិដែលផ្តល់អោយផ្លែមិនគ្រប់គ្រាន់ ការអោយទឹកមិនស្មើគ្នាមានអាការៈខ្វះទឹកច្រើនផងនៅក្នុងរដូវជាប់ផ្លែ ។ ទាំងនេះបើសិនជាកសិករមានការអនុវត្តន៍ថែរក្សា និងអោយដើមធូរេនល្អ ក៏នឹងមិនជួបអាការៈសាច់ក្រិនខ្មៅឡើយ ។

# ឯកសារយោង “ References ”

*អត្ថបទដើម (ភាសាថៃ) Original Text (Thai Language):*

Agriculture Support Group, By Vann Thana Busab and Montry Vong Phanith (1st Edition) Office 1074; Bangkok Thailand,

*រូបភាពទាំងនេះគូរដោយ*

*លោក សោម សារ៉ាត មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមភ្នំពេញ កម្ពុជា ខែតុលា ឆ្នាំ 1997*

*Artwork by:* Sarath, Som. Center for Social Development. Phnom Penh, Cambodia, October 1997.

*បកប្រែដោយគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែខេត្តតំបន់ពាយ័ព្យ ប្រទេសកម្ពុជា ថវិកាដែលផ្តល់សំរាប់ចងក្រងសៀវភៅនេះឧបត្ថម្ភដោយកម្មវិធីសិលា*

*Translation by the Cambodia Northwest Provinces Fruit Culture Development Committee. Support for the production of this book provided through the SEILA Programme.*

*Computer file:* TREEBK11.DOC

*បោះពុម្ពលើកទីមួយ (ខែកុម្ភៈ ឆ្នាំ 1998) 500 ក្បាល*

*First Printing (February 1998): 500 copies*

*ហាមថតចម្លងនិងហាមលក់បើគ្មានការអនុញ្ញាត្តិពីគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែខេត្តតំបន់ពាយ័ព្យ*

***This book is not for sale nor to be re-printed without consent of the Author or the Cambodia North-West Provinces Fruit Culture Development Committee.***

# សមាសភាព
# គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែខេត្តតំបន់ពាយ័ព្យ

| លរ. | នាម និងគោត្តនាម | មុខងារ | មកពីខេត្ត |
|---|---|---|---|
| 1. | លោក ផង់ ប៊ុនសួរ | ប្រធានគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បន្ទាយមានជ័យ |
| 2. | លោក ធៀន ចិន្ត | អនុប្រធានគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បាត់ដំបង |
| 3. | លោក អ៊ុង អេន | លេខាធិការគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បាត់ដំបង |
| 4. | លោក ស្រី អឿន | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បាត់ដំបង |
| 5. | លោក គង់ ចន្ថា | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | សៀមរាប |
| 6. | លោក គាន គិលៀន | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | សៀមរាប |
| 7. | លោក សេក សារ៉ុន | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | ពោធិសាត់ |
| 8. | លោក ផា ភិរុណ | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | ពោធិសាត់ |
| 9. | លោក សៀង គង់ | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | ពោធិសាត់ |
| 10. | លោក សាន ស៊ីម៉េង | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បន្ទាយមានជ័យ |
| 11. | លោក គង់ ប៊ុនធឿន | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បន្ទាយមានជ័យ |
| 12. | កញ្ញា អៀង ង៉ឹម | សមាជិកគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | សៀមរាប |
| 13. | លោក ម៉ក់ សឿន | នាយកដ្ឋានក្សេត្រសាស្ត្រ | ភ្នំពេញ |
| 14. | កញ្ញា ខាយលី ចូន | អ្នកជំនាញការសេវាកម្មឈើហូបផ្លែ | បាត់ដំបង |
| 15. | លោក ស៊ាង ឈឿត | ទីប្រឹក្សាគណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ | បាត់ដំបង |
| 16. | លោក អ៊ិត សុផល | ទីប្រឹក្សាផ្នែកកសិកម្មអង្គការវៃរ៉េ | បាត់ដំបង |

**សរុបទាំងអស់មានចំនួន 16 នាក់**

វាយកំព្យូទ័រ (Computer) ដោយលោក ញូ ផាលី